01329265

**Declassified to Public**
**12 June 2020**

D193/66

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Sep-2016, 13:20
CMS/CFO: Ly Bunloung

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

## ដីកាដកការកោសលប់ពីឯកសារនៃសំណុំរឿង ០០៤ ដែលត្រូវបានដាក់បង្ហាញពីពេលមុននៅក្នុងសំណុំរឿង ០០២

---

**ផ្ញើជូន៖** **អង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

## I- ប្រវត្តិនីតិវិធី

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

2. ចាប់តាំងពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៣ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon បានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារមួយចំនួនពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ដោយសារភាពពាក់ព័ន្ធរបស់វាទៅនឹងបញ្ហានានាក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះរបស់ជនជាប់ចោទក្នុងសំណុំរឿងនោះ។ ដោយពិចារណាអំពីដំណាក់កាលនៃកិច្ចស៊ើបសួរ និងប្រភេទនៃសម្ភារៈដែលត្រូវបានដាក់បង្ហាញ គាត់បានបង្កើតការដាក់កំហិត និងទម្រង់បែបបទមួយចំនួនស្តីពីការដាក់បង្ហាញចម្លើយទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២។ ក្នុងចំណោមនោះគឺការកោសលប់សម្ភារៈដែលត្រូវបានចាត់ទុកថាប៉ះពាល់ដល់កិច្ចស៊ើបសួរដែលកំពុងប្រព្រឹត្តទៅ ឬព័ត៌មានដែលត្រូវបានចាត់ទុកថាមិនពាក់ព័ន្ធនឹងភស្តុតាងដែលត្រូវបានស្នើសុំ។

3. យើងបានពិនិត្យបញ្ជីឈ្មោះសាក្សី និងសម្ភារៈដែលត្រូវបានដាក់បង្ហាញរបស់ពួកគាត់ សម្រាប់តម្រូវការជាបន្តបន្ទាប់ឱ្យមានការកោសលប់ដែលត្រូវបានអនុវត្ត។ ក្នុងការពិនិត្យនេះ យើងរកឃើញថា សម្ភារៈភាគច្រើនក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងដីកានេះ លែងតម្រូវឱ្យមានការកោសលុបមុននេះ ដើម្បីថែរក្សាសុចរិតភាពនៃកិច្ចស៊ើបសួរ។

4. ដីកាសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសម្អាងហេតុខាងលើ យើង៖**

5. **អនុញ្ញាត** ឱ្យដាក់បង្ហាញឯកសារចំនួន ២៩ ទាំងស្រុង និងក្នុងទម្រង់មិនកោសលុប ទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២/០២។ និង

6. **ដាក់ប្រភេទ ក** ទៅក្នុងបញ្ជីសាក្សីទាំងឡាយដែលមានក្នុង **ឧបសម្ព័ន្ធ ក** អនុលោមតាមវិធានការនានាដែលត្រូវបានបង្ហាញក្នុងអនុស្សរណៈចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥[1] ដោយសារភាព

---

[1] សំណុំរឿង ០០៤-D273, *អនុស្សរណៈពី ស.ច.ស.អ ទៅ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាក់ទង "ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅសំណុំរឿង ០០២"*, ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("អនុស្សរណៈ D273")។

សម្ងាត់ និងភាពរសើបនៃកិច្ចស៊ើបសួរដែលកំពុងប្រព្រឹត្តទៅ នឹងមានទម្រង់បែបបទ និងការកំហិតដូចខាងក្រោមស្ដីពីការប្រើប្រាស់ភស្តុតាងរបស់ពួកគាត់៖

(ក) សម្ភារៈទាំងអស់ដែលបានផ្ដល់ពីសំណុំរឿង 00៤ ត្រូវបានចាត់ទុកជាសម្ភារៈសម្ងាត់។

(ខ) ក្នុងករណីដែលឯកសា រដែលបានផ្ដល់អនុលោមតាមដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង00២/0១ ឯកសារទាំងនោះត្រូវចាត់ទុកជាឯកសារសម្ងាត់។

(គ) គ្មានសម្ភារៈណាមួយដែលត្រូវបានផ្ដល់អនុលោមតាមដីកាសម្រេចនេះ ត្រូវបានផ្សព្វផ្សាយឲ្យហួសពីអ្វីដែលត្រូវបានបង្ហាញជាក់លាក់នៅក្នុងដីកានេះឡើយ។

(ឃ) ក្នុងករណីដែលសាក្សីដែលកំណត់ហេតុស្ដាប់ចម្លើយរបស់ពួកគាត់ ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញក្នុង**ឧបសម្ព័ន្ធ ក** ត្រូវបានកោះហៅឲ្យផ្ដល់សក្ខីកម្ម ពួកគាត់អាចធ្វើដូច្នោះក្នុងសវនាការជាចំហរ ល្ពឹកណាឈ្មោះ និងព័ត៌មានអត្តសញ្ញាណដទៃទៀតរបស់ពួកគាត់ ត្រូវរក្សាជាសម្ងាត់។

(ង) ភាគី មេធាវីការពារក្ដីណា ឬបុគ្គលដទៃទៀតដែលអានពី លើកឡើង ឬប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយដែលត្រូវបានដាក់បង្ហាញក្នុង **ឧបសម្ព័ន្ធ ក** ត្រូវសម្គាល់សាក្សីតាមរយៈរហស្សនាមរបស់គាត់ដែលត្រូវបានដាក់ឲ្យសម្រាប់សំណុំរឿង00២/0២ និងប្រើប្រាស់ការពិពណ៌នានានាដែលត្រូវបានពិចារណាដោយសមហេតុផលដើម្បីបញ្ចៀសការកំណត់អត្តសញ្ញាណសាក្សីតាមរយៈព័ត៌មានដទៃទៀត។

(ច) គ្មានសម្ភារៈណាមួយដែលត្រូវបានផ្ដល់អនុលោមតាម **ឧបសម្ព័ន្ធ ក** ត្រូវបានផ្សព្វផ្សាយទៅសាធារណជនក្នុងទម្រង់ណាមួយឬតាមរយៈទម្រង់ណាមួយនៃប្រព័ន្ធផ្សព្វផ្សាយហួស ពីភស្តុតាងដែលបានបង្ហាញក្នុងសវនាការជាចំហរឡើយ។

(ឆ) កំណត់ហេតុនៃការស្ដាប់ចម្លើយដែលត្រូវបានអនុញ្ញាត ត្រូវប្រគល់ទៅមេធាវីការពារក្ដីរបស់ជនជាប់ចោទទាំងអស់, មេធាវីការពារក្ដីប្រចាំការរបស់ ខៀវ សំផន ("មេធាវីការពារក្ដីប្រចាំការ") និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈសំណៅអេឡិចត្រូនិក។

(ជ) មេធាវីការពារក្ដី មេធាវីការពារក្ដីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញឯកសារដែលបានផ្ដល់ឲ្យ អនុលោមតាមដីកាសម្រេចនេះ ជូនទៅសមាជិកទាំងឡាយនៃក្រុមរបស់ផងខ្លួន ដែលត្រូវបានជួលជាផ្លូវការក្រោមវិធាន២២(៥) នៃវិធានផ្ទៃក្នុង និងវិធាន១២*ស្ទួនពីរ*(៤) ព្រមជាមួយបុគ្គលិកហាត់ការរបស់ខ្លួនដែលត្រូវបានតែងតាំងជាផ្លូវការប៉ុណ្ណោះ។

(ឈ) មេធាវីការពារក្តី មេធាវីការពារក្តីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំត្រូវបានអនុញ្ញាតឲ្យព្រីន ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងសំណៅនានានៃឯកសារដើមដែលត្រូវបានផ្តល់ទៅពួកគាត់ ឲ្យហួសពីការប្រើប្រាស់ផ្ទៃក្នុងនូវសម្ភារៈនោះពីសំណាក់សមាជិកទាំងឡាយនៃក្រុមនីមួយៗរបស់ពួកគាត់ ដែលត្រូវបានណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យសម្ភារៈសម្ងាត់ឡើយ។

(ញ) មេធាវីការពារក្តី មេធាវីការពារក្តីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវថែរក្សាកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយ ក្នុងលក្ខណៈដែលអាចពិនិត្យមើលបាន នូវសំណៅនានាដែលពួកគាត់ព្រីន ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និង

(ដ) ប្រសិនបើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២ ដឹងអំពីការចម្លងដោយគ្មានការអនុញ្ញាតនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីសម្រាប់ ការដាក់បង្ហាញ ខ្លួនត្រូវចាត់វិធានការទាំងអស់ជាបន្ទាន់ដើម្បីទទួលបាន និងប្រគល់សងវិញនូវសំណៅនោះ ជូន ស.ច.ស និង

(ឋ) ប្រសិនបើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២ ដឹងអំពីការរំលោភលក្ខខណ្ឌ និងការកំហិតទាំងនេះ ខ្លួនត្រូវរាយការណ៍អំពីការរំលោភនេះ ជូន ស.ច.ស។

7. **ដាក់ប្រភេទ គ** ទៅក្នុងបញ្ជីសាក្សីទាំងពីរដែលមានឈ្មោះក្នុង **ឧបសម្ព័ន្ធ ខ** អនុលោមតាមវិធានការនានាដែលត្រូវបានបង្ហាញក្នុងអនុស្សរណៈ D273 ដែលដោយសារភាពសម្ងាត់ និងភាពរសើបនៃកិច្ចស៊ើបសួរដែលកំពុងប្រព្រឹត្តទៅ នឹងមានទម្រង់បែបបទដូចខាងលើ ប៉ុន្តែសម្រាប់កថាខណ្ឌ ៦(ឃ) ដល់ ៦(ច) ដែលត្រូវបានជំនួសដោយការកំហិតដែលតឹងរ៉ឹងជាងមុន៖

(ឃ) ក្នុងករណីដែលសាក្សីដែលឯកសាររបស់ពួកគាត់ ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញក្នុង **ឧបសម្ព័ន្ធ ខ** ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ពួកគាត់ត្រូវធ្វើដូច្នោះក្នុងសវនាការជាអសាធារណៈ។

(ង) ភាគី មេធាវីការពារក្តីណា ឬបុគ្គលដទៃទៀតដែលអានពី លើកឡើង ឬប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានដាក់បង្ហាញក្នុង **ឧបសម្ព័ន្ធ ខ** ត្រូវស្នើសុំសវនាការជាអសាធារណៈ មុនពេលធ្វើដូច្នោះ និងសម្គាល់សាក្សីតាមរយៈរហស្សនាមរបស់គាត់ដែលត្រូវបានដាក់ឲ្យសម្រាប់សំណុំរឿង ០០២/០២ និងប្រើប្រាស់ការពិពណ៌នានានា ដែលត្រូវបានពិចារណាដោយសមហេតុផលដើម្បីបញ្ចៀសការ កំណត់អត្តសញ្ញាណសាក្សីតាមរយៈព័ត៌មានដទៃទៀត។

(ច) គ្មានសម្ភារៈណាមួយដែលត្រូវបានផ្តល់អនុលោមតាម **ឧបសម្ព័ន្ធ ខ** ត្រូវបានផ្សព្វផ្សាយ ទៅសាធារណជនក្នុងទម្រង់ណាមួយ ឬតាមរយៈទម្រង់ណាមួយនៃប្រព័ន្ធផ្សព្វផ្សាយ ឬត្រូវបានបង្ហាញ ឬយោងទៅរកក្នុងសវនាការជាចំហរតាមវិធីណាមួយឡើយ។

ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ភ្នំពេញ

ហត្ថលេខា និងត្រា

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**